ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
លេខ: ២៩/២០១៧ អ.កបធ.សជណ

# សេចក្ដីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ១០:០០ព្រឹក នៅសាលប្រជុំអគារ«ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យ និងសម្រេចលើសំណុំរឿង ៖

១-លេខ៣២៨/០៦៦/២០១៧ លេខ៣២៩/០៦៧/២០១៧ លេខ៣៣០/០៦៨/២០១៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៨១/០២១/២០១៧ កបធ.ច ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ១២២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ លេខ១៤០ លេខ១៥៧ និងលេខ១៥៨ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល។

២-លេខ៣៣១/០៦៩/២០១៧ លេខ៣៣២/០៧០/២០១៧ លេខ៣៣៣/០៧១/២០១៧ លេខ៣៣៤/០៧២/២០១៧ លេខ៣៣៥/០៧៣/២០១៧ លេខ៣៣៦/០៧៤/២០១៧ លេខ៣៣៧/០៧៥/២០១៧ និងលេខ៣៣៨/០៧៦/២០១៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៨២/០២២/២០១៧ កបធ.ច ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយមិនទទួលពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់លោក **ឱន វ៉ារិន** តំណាងឲ្យលោកស្រី **ខឹម ចាន់ធារី** លោក **ម៉ាច វុទ្ធី** លោក **សំ ប៊ុនអាន** លោកស្រី **អ៊ិន សារឿន** និងលោកស្រី **ផឹង ចិន្តា** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៥២ ០៥៣ ០៥៤ ០៥៥ និងលេខ០៥៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយខុសនឹងទម្រង់ច្បាប់ និង តម្កល់សេចក្ដីសម្រេចលេខ០៥២ ០៥៣ ០៥៤ ០៥៥ ០៥៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ១៥២ ១៥៥

និងលេខ១៥៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

៣-លេខ៣៣៩/០៧៧/២០១៧ លេខ៣៤០/០៧៨/២០១៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយបានចេញសេចក្តីសម្រេច លេខ១៨៣/០២៣/២០១៧ កបធ.ច ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្តីសម្រេចលេខ០៥១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ១៦០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

៤-លេខ៣២៧/០៦៥/២០១៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្តីសម្រេចលេខ១៨៤/០២៤/២០១៧ កបធ.ច ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្តីសម្រេចលេខ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៤ ១១៥ ១១៦ ១១៧ ១១៨ ១១៩ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ១៤៧ ១៤៨ ១៤៩ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល តែមិនទទួលពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់លោកមេធាវី **ផែង ហេង** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៤៣ ០៤៤ ០៤៥ ចុះថ្ងៃទី១៩ មករា ឆ្នាំ២០១៧ ដោយខុសនឹងទម្រង់ច្បាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណៈជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧